ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ទីក្រុងគ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

# លិខិតចំហ
## ជំរុញដំណោះស្រាយសំណុំរឿង កោះគុត និងការកំណត់ដែនសមុទ្រកម្ពុជា-ថៃ ទៅកាន់តុលាការអន្តរជាតិ

## សូមជម្រាបជូន
## លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត នៃព្រះរាជាណាចក្រកម្ពុជា

***លោកនាយករដ្ឋមន្ត្រីជាទីគោរពរាប់អាន***

ដោយកត់សម្គាល់ឃើញថា ជាច្រើនសប្តាហ៍មកនេះ មានអ្នកជាតិនិយម និងពលរដ្ឋខ្មែររាប់លាននាក់ សម្តែងសេចក្តីព្រួយបារម្ភយ៉ាងខ្លាំងនៅលើបណ្តាញសង្គម ជុំវិញបញ្ហាវិវាទ«**កោះគុត និងដែនសមុទ្រកម្ពុជា-ថៃ**» ខណៈពេលអ្នកជាតិនិយមថៃ និងមេដឹកនាំថៃ បញ្ជាក់ជំហរម្តងហើយម្តងទៀតនូវ **កោះគុតជារបស់ថៃ** និងមិនផ្តល់តម្លៃពេញលេញ ទៅលើអនុស្សារណៈនៃការយោគយល់គ្នាឆ្នាំ២០០១ (MOU-2001) រវាងកម្ពុជា-ថៃ ស្តីពីតំបន់ត្រួតស៊ីគ្នា (Overlapping Claims Areas (OCA))។

យោងតាមបទពិសោធន៍ជាប្រវត្តិសាស្ត្ររបស់កម្ពុជាពីអតីតកាល បញ្ជាក់ថា រដ្ឋាភិបាលថៃ បានប្រើយោធាដណ្តើមកាន់កាប់ប្រាសាទព្រះវិហាររបស់កម្ពុជា នៅឆ្នាំ១៩៥៤ រហូតដល់កម្ពុជា បានឈ្នះក្តីក្នុងសំណុំរឿងនេះ នៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) នាឆ្នាំ១៩៦២ ទើបភាគីថៃ យល់ព្រមដកកងទ័ពចេញពីតំបន់ប្រាសាទព្រះវិហារ។ កាលនោះ រដ្ឋាភិបាលកម្ពុជា ក៏ធ្លាប់បានប្រើយន្តការចរចាទ្វេភាគីដែរ មុនពេលប្តឹងប្តល់ទៅតុលាការយុត្តិធម៌អន្តរជាតិ ប៉ុន្តែភាគីថៃ នៅតែមិនព្រមដកថយពីប្រាសាទព្រះវិហារ។ ម្ល៉ោះហើយ កម្ពុជាសម្រេចប្តឹងប្តល់ប្រទេសថៃនៅឆ្នាំ១៩៥៩។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** យល់ឃើញថា រដ្ឋាភិបាលកម្ពុជា ល្មមដល់ពេលបញ្ឈប់យន្តការចរចាទ្វេភាគី ជាមួយរដ្ឋាភិបាលថៃ តទៅទៀត ពីព្រោះវាគ្មានលទ្ធផលល្អសម្រាប់កម្ពុជាទេ ក្នុងរឿង«**តំបន់ត្រួតស៊ីគ្នា**» រួមទាំង **កោះគុត** ផង។

កោះគុត ជាកម្មសិទ្ធិមួយផ្នែករបស់កម្ពុជា ស្របតាមអនុប្រការ ១ និង ២ នៃសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៧ ដែលបញ្ជាក់ច្បាស់លាស់ថា **ខ្សែបន្ទាត់មូលដ្ឋាននៃការកំណត់ព្រំដែនសមុទ្រ រវាងកម្ពុជា និងថៃ គឺត្រូវបានកំណត់នៅលើចំណុចខ្ពស់**

**បំផុត**(កំពូលភ្នំខ្ពស់ជាងគេ) **នៃកោះគុត ដោយរាប់ពីបង្គោលលេខ ៧៣ នៅតំបន់ឆ្នេរ** ដែលមានភ្ជាប់«**ផែនទី**»ឧបសម្ព័ន្ធនៃសន្ធិសញ្ញានេះ។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមជូនយោបល់ដល់**លោកនាយករដ្ឋមន្ត្រី** ជ្រាបថា រដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវប្ដឹងប្រទេសថៃ ទៅកាន់តុលាការអន្តរជាតិ ក្នុងសំណុំរឿង«**កោះគុត» និង ការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ**។ កម្ពុជាអាចប្រើយន្តការតុលាការណាមួយដូចជា តុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice (ICJ)) ឬ តុលាការមជ្ឈត្តិការអន្តជាតិ (Permenent Court of Arbitration (PCA))។ ជាមួយយន្តការនេះ កម្ពុជាត្រូវប្រើច្បាប់អន្តរជាតិ ចំនួន ៣ យ៉ាងតិចរួមមាន សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ស្ដីពីបូរណភាពទឹកដីអធិបតេយ្យរបស់កម្ពុជា និង ច្បាប់សមុទ្រ UNCLOS-1982។

ក្នុងខណៈពេលនេះ រដ្ឋាភិបាលកម្ពុជា គប្បីបញ្ជាក់ជំហរឲ្យច្បាស់លាស់ និងម៉ឺងម៉ាត់បំផុត ៣ យ៉ាងគឺ ៖

**ទី១.** ជម្រាបជូនពលរដ្ឋខ្មែរថា រដ្ឋាភិបាលកម្ពុជា សម្រេចលុបចោល MOU ឆ្នាំ២០០១ ជំនួសដោយយន្តការអន្តរជាតិ ដើម្បីកំណត់ខ្សែបន្ទាត់ព្រំដែនសមុទ្រជាមួយរដ្ឋាភិបាលថៃ ជាមុនសិន។

**ទី២.** ត្រូវធ្វើកំណត់ទូត តវ៉ាទៅកាន់រដ្ឋាភិបាលថៃ ថា មួយផ្នែកនៃ កោះគុត គឺជា កម្មសិទ្ធិរបស់កម្ពុជា។

**ទី៣.** រៀបចំសំណុំឯកសារប្ដឹងប្ដល់ប្រទេសថៃ ទៅតុលាការអន្តរជាតិ ជាផ្លូវការ។

## *លោកនាយករដ្ឋមន្ត្រីជាទីគោរពរាប់អាន*

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា** សូមរំឭកជូនបន្ថែមថា ថ្វីត្បិតបន្ទុករបស់រដ្ឋាភិបាលកម្ពុជា មានបញ្ហាជាច្រើនត្រូវដោះស្រាយក៏ពិតមែនហើយ ប៉ុន្តែ **ពុំគួរណាបន្តខុសឆ្គងតទៅទៀតទេ** ទៅលើបញ្ហាកំណត់ខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជិតខាង ទាំងព្រំដែនគោក និងព្រំដែនទឹក រួមទាំងករណី កោះត្រល់ និងចង្កោមកោះក្រចកសេះ ជាមួយប្រទេសវៀតណាមផង។ ការខុសឆ្គងទៅលើរឿងជាតិទឹកដី គួបផ្សំរឿងអយុត្តិធម៌សង្គមដទៃទៀតផងនេះ ពិតជារឿងធ្ងន់ធ្ងរណាស់ មិនអាចធានាតួនាទីនៅក្នុងរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី ឲ្យបាននឹងន់យូរអង្វែងទេ ពីព្រោះទាំងនោះគឺជាកំហុសឆ្គង រំលោភបំពានរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងច្បាប់វិជ្ជមាននានារបស់កម្ពុជា។

**សូមលោកនាយករដ្ឋមន្ត្រី** ទទួលនូវការគោរពរាប់អានដ៏ខ្ពស់ខ្ពស់អំពីយើងខ្ញុំ។

**ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**



**ម៉ែន ណាត**

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Homepage: https://cwcicambodia.net